**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ**
លេខ: ១០៣ សអស អកធ.បស្ត

អាចពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការងារសាងសង់បង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិ នៅដែនជម្រកសត្វព្រៃតាតៃ ខេត្តកោះកុង និងនៅដែនជម្រកសត្វព្រៃស្រែពក ដែនជម្រកសត្វព្រៃកែវសីមា ភូមិសាស្ត្រខេត្តមណ្ឌលគិរី ឆ្នាំ២០១៨
## ទំហំ កំពស់ ១,៥ម x បន្ទារ( ០,៥ម x ០,៩ម )+( ០,៧ម x ០,៦ម ) x កំរាស់០,២ម

អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា អគ្គនាយកដ្ឋាននឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិ នៅដែនជម្រកសត្វព្រៃតាតៃ ខេត្តកោះកុង។

ក្រុមលទ្ធកម្មនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅនាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ (បន្ទប់បូកគោ ជាន់ទី២) ដែលមានអាសយដ្ឋាន អគារមរតកតេជោ ផ្លូវលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង៨ៈ០០ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៨។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ តាមអាសយដ្ឋានខាងលើ វេលាម៉ោង ៨ៈ០០ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៨។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មនៃអគ្គនាយកដ្ឋាន ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ សុក្រ ១១ កើត ខែ អាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៨
**ជ.អគ្គនាយក**
**និងជាប្រធានក្រុមលទ្ធកម្ម**

អគ្គនាយកដ្ឋានរដ្ឋបាល ការពារ និង អភិរក្ស ធម្មជាតិ

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ កាលប្បវត្តិ

*ឯកសារដេញថ្លៃសំណង់ ទំព័រទី ១*